**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការសំរាប់តាមដានការអនុវត្តកិច្ចសន្យា សម្បទានព្រលានយន្តហោះភ្នំពេញ និងសៀមរាប

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## ស ំ រេ ច

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មការមួយ ដើម្បីតាមដានការអនុវត្តកិច្ចសន្យាសម្បទានព្រលានយន្តហោះភ្នំពេញ និងសៀមរាប ក្នុងគោលបំណងធានាប្រសិទ្ធភាពនៃការអនុវត្តនេះ ទាំងលើវិស័យសង្គម វិស័យបច្ចេកទេស និងវិស័យហិរញ្ញវត្ថុ ។

**មាត្រា ២.-**

សមាសភាពនៃគណៈកម្មការនេះ រួមមាន :

១- ឯកឧត្តម **សុខ អាន** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន

២- ឯកឧត្តម **ញូណរ ឡេង** តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៣- ឯកឧត្តម **ឆា សុផ្លា** តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាសមាជិក

៤- ឯកឧត្តម **សុខ ចិន្តា** តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

ប្រធានអាចជ្រើសរើសអ្នកច្បាប់មួយរូបដើម្បីធ្វើកំណត់ហេតុនៅពេលប្រជុំ ។

**មាត្រា ៣.-**

គណៈកម្មការ ប្រជុំរៀងរាល់បីខែម្តង តាមការកោះអញ្ជើញរបស់ប្រធាន ។ កិច្ចប្រជុំលើកទី១ ត្រូវធ្វើឡើង ៦០ ថ្ងៃ ក្រោយពីថ្ងៃអនុក្រឹត្យនេះ ចូលជាធរមាន ។

ដើម្បីបំពេញបេសកកម្មរបស់ខ្លួន គណៈកម្មការពិនិត្យរបាយការណ៍ដែលក្រុមហ៊ុនសម្បទានព្រលានយន្តហោះ ធ្វើជូនទៀងទាត់ប្រចាំត្រីមាស ហើយដែលមានបញ្ជាក់យ៉ាងល្អិតល្អន់ផងដែរអំពីស្ថានភាពនៃប្រតិបត្តិការសម្បទាននោះ ព្រមស្ថិតិទាំងឡាយទាក់ទងនឹងប្រតិបត្តិការនេះ ។ របាយការណ៍របស់ក្រុមហ៊ុនមានចុះផងដែរនូវចំណុចទាំងឡាយដែលជាភាពរអាក់រអួលនៃប្រតិបត្តិការនោះ ។

គណៈកម្មការព្យាយាមដោះស្រាយបញ្ហាទាំងឡាយ ជាមួយនឹងក្រសួង និងបណ្តាក្រសួងពាក់ព័ន្ធផ្សេងទៀត ហើយធ្វើរបាយការណ៍សរុបជូនរាជរដ្ឋាភិបាល ។

គណៈកម្មការអាចតម្រូវឱ្យក្រុមហ៊ុនសម្បទានកែលំអនូវសកម្មភាពប្រតិបត្តិការរបស់ខ្លួន បើគណៈកម្មការយល់ឃើញថា មានការខ្វះខាត ។

**មាត្រា ៥.-**

ក្នុងករណី ដែលការពិភាក្សា រវាងគណៈកម្មការនិងក្រុមហ៊ុនសម្បទាន បង្ហាញថា មានចំណុចមួយឬមួយចំនួននៃកិច្ចសន្យាដើម និងកិច្ចសន្យាបន្ថែមបន្តបន្ទាប់មកទៀត តម្រូវឱ្យមានការកែលំអ ឬការបន្ថែមបន្ថយ គណៈកម្មការត្រូវរៀបចំកិច្ចសន្យាបន្ថែមមួយទៀត នឹងដាក់ជូនរាជរដ្ឋាភិបាល និងក្រុមហ៊ុនសម្បទាន ចុះហត្ថលេខា មិនឱ្យហួសថ្ងៃទី ៣១ ខែមករា ឆ្នាំ២០០៤ ។

**មាត្រា ៦.-**

គណៈកម្មការ មានសិទ្ធិទាមទារគ្រប់ឯកសារនិងពត៌មានទាំងឡាយពីក្រុមហ៊ុនសម្បទាន ក៏ដូចជាក្រសួងនានាដើម្បីសម្រេចបេសកម្មរបស់ខ្លួន ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៣*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៧*
- *ឯកសារ_កាលប្បវត្តិ*